ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ២៥៥

ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១

សាលដីកា

លេខ ២០៨ "III"

ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២

ដោយអង្គជំនុំជម្រះដែលមានសមាសភាពដូចខាងក្រោម ៖

១-ឯកឧត្តម [redacted] ជាប្រធាន

២-ឯកឧត្តម [redacted] ជាចៅក្រម

៣-ឯកឧត្តម [redacted] ជាចៅក្រម

៤-ឯកឧត្តម [redacted] ជាចៅក្រម

៥-ឯកឧត្តម [redacted] ជាចៅក្រម

**ចៅក្រមរបាយការណ៍**

ឯកឧត្តម [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ឋានៈជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ១៧៧ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ខែសា និង [redacted] ផានី ក្នុងការប្តឹងសាទុក្ខចំពោះសាលដីកាព្រហ្មទណ្ឌលេខ ២៩ ក្រIV "ណ" ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលមាន៖

**បុគ្គលប្តឹងសាទុក្ខ ៖**

១-ជនជាប់ចោទឈ្មោះ [redacted] ខែសា ហៅ សាស ភេទប្រុស កើតថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០០ ជនជាតិខ្មែរ មានកន្លែងកំណើតនៅភូមិក្រយាជើង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ មានលំនៅមុនពេលឃុំ [redacted] ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ។ នៅលីវ ។ ទោសពីមុនគ្មាន ។



Scanned with CamScanner

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៣៩៣/១៧ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ពន្ធនាគារខេត្តកំពង់ធំ។

-លោក [redacted] បូរ៉ា ជាមេធាវីការពារ ។

២-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៩ ជនជាតិខ្មែរ មានកន្លែងកំណើតនៅភូមិក្រយាត្បូង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ មានលំនៅមុនពេលឃុំខ្លួននៅភូមិក្រយា [redacted] ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] " ។ នៅលីវ ។ ទោសពីមុនគ្មាន ។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៣៩៤/១៧ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២០១៧ ពន្ធនាគារខេត្តកំពង់ធំ។

-លោក [redacted] បូរ៉ា ជាមេធាវីការពារ ។

**ជាប់ចោទពីបទ** ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅចំណុចភូមិក្រយាត្បូង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ។

**បុគ្គលដែលពាក់ព័ន្ធ ៖**

៣-ជនជាប់ចោទឈ្មោះ [redacted] **ទាង** ភេទប្រុស អាយុ ២០ ឆ្នាំ ជនជាតិខ្មែរ កើតនិងរស់នៅភូមិក្រយាជើង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ។

**ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted] លេម ភេទស្រី អាយុ ៥២ឆ្នាំ ជនជាតិខ្មែរ មានលំនៅភូមិសុផុស ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ។

**<u>អំពីអង្គហេតុ៖</u>**

កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង ២០ និង ៣០នាទី ស្ថិតនៅចំណុចផ្លូវកែង ខាងជើងស្ពានផ្លងស្ទឹងអន្លង់ជួរ ចម្ងាយប្រហែល ៤០០ ម៉ែត្រ ខាងជើងភូមិក្រយាត្បូង ឃុំក្រយា ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ឈ្មោះ [redacted] ខែសា ,ឈ្មោះ [redacted] ផានី ,ឈ្មោះ [redacted] ទាង និងបក្ខពួកបានផឹកស៊ីស្រវឹង ហើយបានទៅពួនស្ទាក់ផ្លូវចាំវាយលើជនរងគ្រោះឈ្មោះ [redacted] សាយ បណ្តាលឱ្យស្លាប់បាត់បង់ជីវិតនៅកន្លែងកើតហេតុតែម្តង ។

-បានឃើញ សាលក្រមលេខ ២៦ (ខ) ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ធំដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ផ្តន្ទាទោសជនជាប់ចោទ៖

១-ឈ្មោះ [redacted] ខែសា ហៅ សាល ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ (មានសាវតារជាតិដូចខាងលើ)

២-ឈ្មោះ [redacted] ផានី ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ (មានសាវតារជាតិដូចខាងលើ)

៣-ឈ្មោះ [redacted] ទាង ភេទប្រុស អាយុ ២០ឆ្នាំ (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់រយៈពេល ១៥ (ដប់ប្រាំ) ឆ្នាំ ពីបទឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិក្រយាត្បូង ឃុំក្រយា ស្រុក



Scanned with CamScanner

ប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ២០០ និងមាត្រា៩៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

២-បង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ទាង ភេទប្រុស អាយុ ២០ ឆ្នាំ ជាតិខ្មែរ(មានសាវតារជាតិដូចខាងលើ) យកមកអនុវត្តទោសដាក់ពន្ធនាគារក្នុងពន្ធនាគារខេត្តកំពង់ធំ តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] ខែសា ហៅ សាល, ឈ្មោះ [redacted] ផានី និងឈ្មោះ ទូច ទាង រួមគ្នាសងសំណងរដ្ឋប្បវេណីឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] លេម ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ទាមទារលើសពីនេះបដិសេធចោល ។

៤-វត្ថុតាងមាន៖ ១.ដំបងឈើមូលប្រវែង ១៧០ស.ម ទំហំ១៧ ស.ម ចំនួន០១ , ២.ដំបងឈើមូលប្រវែង ១៤៤ ស.ម ទំហំ ១១ ស.ម ចំនួន ០១ , ៣.ដំបងឈើមូលប្រវែង ៩៦ស.ម ទំហំ ១៥ស.ម ចំនួន០១, ៤. ដំបងឈើមូលប្រវែង ៩៨ស.ម ទំហំ ១៧ស.ម ចំនួន០១ , ៥.ស្បែកជើងផ្ទាត់ពណ៌សចំនួន០១គូ , ៦.ស្បែកជើងកាម្មីពណ៌ឈាមជ្រូកចំនួន ០១ និង៧.ស្បែកជើងស៊ិកស្នោ ពណ៌ខ្មៅ ០១ចំហៀង រឹបអូសបំផ្លាញចោល។

៥-សាលក្រមនេះជំនុំជម្រះបានបញ្ចប់ការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ខែសា ហៅ សាល និងឈ្មោះ [redacted] ផានី និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ទាង និងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] លេម ។

ទុកសិទ្ធិឱ្យភាគីអវត្តមានប្ដឹងទាស់និងទុកសិទ្ធិឱ្យគូភាគីប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ១២ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ផានី និងឈ្មោះ [redacted] ខែសា ក្នុងការប្ដឹងឧទ្ធរណ៍ ដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ២៦ (ខ) ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ធំ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ២៩ ក្រIV “ណ” ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១-បដិសេធពាក្យបណ្ដឹងឧទ្ធរណ៍លេខ ១២ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ផានី និងឈ្មោះ [redacted] ខែសា ចោលជាអសារបង់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៦ “ខ” ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ធំទុកជាបានការ ។

៣-បន្តការឃុំខ្លួនជនជាប់ចោទទាំងពីររូបតាមច្បាប់។

សាលដីកានេះជំនុំជម្រះនាសវនាការជាអសាធារណៈ នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០២១ កំបាំងមុខជនជាប់ចោទទាំងពីររូប និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ កំបាំងមុខជនជាប់ចោទទាំងពីររូប ទុកសិទ្ធិឱ្យប្ដឹងទាស់និងប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ១៧៧ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted]ខែសា និងឈ្មោះ [redacted]ផានី ក្នុងការប្តឹងសាទុក្ខ បានប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ២៩ ក្រIV "ណ" ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២ របស់សាលាឧទ្ធរណ៍ភ្នំពេញត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សារណាការពារ ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted]ខែសា។

-បានឃើញ សារណាការពារ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted]ផានី ។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍ឡើងធ្វើសេចក្តីរាយការណ៍ ។

-សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលបានលើកឡើងថា សាលាឧទ្ធរណ៍បានសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៦ (ខ) ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ធំទុកជាបានការនោះ គឺត្រឹមត្រូវហើយ ។ យោងតាមចម្លើយសារភាពរបស់ជនជាប់ចោទទាំងពីរនាក់នៅដំណាក់កាលសាលាដំបូងបានឆ្លើយថា ពួកខ្លួនពិតជាបានពួនស្ទាក់ចាំចាប់ជនរងគ្រោះ និងវាយជនរងគ្រោះបណ្តាលឱ្យស្លាប់ប្រាកដមែន ។ ចម្លើយសារភាពទាំងអស់នេះបានស៊ីចង្វាក់គ្នាទៅនឹងភស្តុតាងដែលសមត្ថកិច្ចបានចាប់យកទៅនឹងកន្លែងកើតហេតុ មាននៅក្នុងសំណុំរឿង កំណត់ហេតុដកហូតស្រាប់ជាភស្តុតាង ។ រាល់ទង្វើរបស់ជនជាប់ចោទពិតជាមានភស្តុតាងនិងពិរុទ្ធភាពគ្រប់គ្រាន់ ពីបទឃាតកម្មគិតទុកជាមុន ដែលតម្រូវឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ។ ដូចនេះផ្អែកតាមសំអាងហេតុរបស់សាលាឧទ្ធរណ៍ដែលបានបញ្ជាក់ស្រាប់ត្រង់ចំណុចទី២ ,ទី៣ និងទី៤ ស្រាប់ ។ តំណាងមហាអយ្យការសុំតម្កល់សាលាដីកាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការដដែល ។

-លោក [redacted]បូរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនប្តឹងសាទុក្ខមកតុលាការកំពូលពីព្រោះមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចផ្អែកលើសំអាងហេតុស្លាប់តែខាងភាគីជនរងគ្រោះ អង្គហេតុកើតឡើងមានតែជនជាប់ចោទនិងជនរងគ្រោះ ពុំមានសាក្សីបានឃើញទេ ។ ម្យ៉ាងទៀតជនរងគ្រោះមិនបានស្លាប់ដោយសារអំពើប្រព្រឹត្តរបស់ជនជាប់ចោទទេ អាចស្លាប់ដោយសារការស្រវឹងស្រា ឬមូលហេតុផ្សេងទៀត ។ យោងតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

**សំណូមពរ ៖** សូមតុលាការកំពូលបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ភ្នំពេញដើម្បីជំនុំជម្រះសាជាថ្មី។

-ជនជាប់ចោទឈ្មោះ [redacted]ខែសា បានឆ្លើយថា ខ្លួនសូមឯកភាពតាមមេធាវីការពារក្តីឱ្យខ្លួន ។

**សំណូមពរ ៖** សូមឱ្យតុលាការកំពូលជួយបន្ធូរបន្ថយទោសដល់រូបខ្លួន ព្រោះខ្លួនជាអនីតិជន ហើយបានផ្តន្ទាទោសរូបខ្លួនស្មើនឹងនីតិជន ដោយខ្លួនគ្រាន់តែស្រវឹងតែប៉ុណ្ណោះ ។

-ជនជាប់ចោទឈ្មោះ [redacted]ផានី បានឆ្លើយថា ខ្លួនសូមឱ្យតុលាការកំពូលជួយបន្ធូរបន្ថយទោសដល់ខ្លួន ព្រោះឆាប់បានចេញទៅមើលថែឪពុកម្តាយចាស់ជរា ។



Scanned with CamScanner

សំណូមពរ ៖ សូមឱ្យតុលាការកំពូលជួយបន្ធូរបន្ថយទោសដល់រូបខ្លួន ដើម្បីឆាប់បានចេញទៅមើលថែឪពុកម្ដាយដែលចាស់ជរា ព្រោះខ្លួនបានប្រព្រឹត្តនៅពេលស្រវឹងស្រា ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] លេម សូមឱ្យតុលាការផ្ដន្ទាទោសជនជាប់ចោទទាំងពីរនាក់អស់មួយជីវិត ។

-ក្រោយពីបានស្ដាប់សេចក្ដីរាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ចម្លើយជនជាប់ចោទ និងសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

## តុលាការកំពូល

១-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ១៧៧ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ខែសារ និងឈ្មោះ [redacted] ផានី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងក្ដីនេះមកជំនុំជម្រះបានតាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤១៧ ,មាត្រា ៤១៨ និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ភ្នំពេញបានសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៦ “ខ” ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ធំ ត្រង់ចំណុចទី១ នៃសេចក្ដីសម្រេច ដោយផ្ដន្ទាទោសជនជាប់ចោទ ១.ឈ្មោះ [redacted] ខែសា ភេទប្រុស អាយុ១៧ ឆ្នាំ ២.ឈ្មោះ [redacted] ផានី ភេទប្រុស អាយុ១៨ ឆ្នាំ ៣.ឈ្មោះ [redacted] ទាង ភេទប្រុស អាយុ ២០ ឆ្នាំ ដាក់ពន្ធនាគារម្នាក់ៗ កំណត់រយៈពេល ១៥ឆ្នាំ ពីបទឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិក្រយាខាងត្បូង ឃុំក្រយា ស្រុកប្រាសាទបាល្ល័ង្ក ខេត្តកំពង់ធំ កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា២០០ និងមាត្រា៩៥ នៃក្រមព្រហ្មទណ្ឌ ហើយយកមាត្រា៩៥ នៃក្រមព្រហ្មទណ្ឌមកប្រើសម្រាប់សម្រាលទោសទាំងអស់គ្នា ដោយពុំបានគិតដល់ជនជាប់ចោទឈ្មោះ [redacted] ខែសា ជាអនីតិជន នោះជាការពុំត្រឹមត្រូវទេ ដែលជននេះត្រូវពិចារណាដាច់ដោយឡែកតាមបញ្ញត្តិមាត្រា ១៦០ ត្រង់កថាខណ្ឌទី១ ចំណុចទី២ នៃក្រមព្រហ្មទណ្ឌ ។

៣-យល់ឃើញថា ការដែលមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទលើកឡើងថា សាលាឧទ្ធរណ៍សម្រេចសេចក្ដីពុំមានសំអាងហេតុ ស្ដាប់តែខាងភាគីជនរងគ្រោះ អង្គហេតុកើតឡើងមានតែជនជាប់ចោទនិងជនរងគ្រោះ ពុំមានសាក្សីបានឃើញទេ នោះជាការពុំត្រឹមត្រូវទេ ដោយហេតុថា ក្នុងផ្នែកសំអាងហេតុ ត្រង់ចំណុចទី៣ នៃសាលដីកាព្រហ្មទណ្ឌលេខ ២៩ ក្រIV “ណ” ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញបានលើកបង្ហាញច្បាស់លាស់ហើយ ។ ឯការលើកឡើងរបស់មេធាវីការពារឱ្យជនជាប់ចោទដែលបានអះអាងថា ជនរងគ្រោះមិនស្លាប់ដោយសារអំពើប្រព្រឹត្តដោយផ្ទាល់របស់ជនជាប់ចោទទេ អាចស្លាប់ដោយសារ



Scanned with CamScanner

ការស្រវឹងស្រា ឬ ដោយមូលហេតុផ្សេងទៀត នោះជាសេចក្ដីសន្និដ្ឋានមិនមានមូលដ្ឋានសំអាងលើភស្តុតាងនោះឡើយ គ្រាន់តែជាការស្មានប៉ុណ្ណោះ ។ ចំណែកឯផ្នែកសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារបានលើកឡើងថា ការដែលសាលាឧទ្ធរណ៍បានសម្រេចផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ខែសា ជាអនីតិជនស្មើនឹងជនជាប់ចោទពីរនាក់ទៀតជាជនមាននីតិភាព ដោយសំអាងលើបញ្ញត្តិមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ នោះគឺជាសេចក្ដីសន្និដ្ឋានមានមូលដ្ឋានអង្គច្បាប់សមស្រប។

៤-យល់ឃើញថា សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការបានលើកឡើងថា បណ្ដឹងសាទុក្ខលេខ ១៧៧ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ខែសារ និងឈ្មោះ [redacted] ធានី ធ្វើឡើងក្នុងកំណត់ច្បាប់ ។ សាលាឧទ្ធរណ៍បានសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៦ "ខ" ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ធំ ទុកជាបានការគឺជាការត្រឹមត្រូវ។ ដោយយោងតាមចម្លើយសារភាពរបស់ជនជាប់ចោទទាំងពីរនាក់នៅដំណាក់កាលសាលាដំបូងបានឆ្លើយថា ពួកខ្លួនពិតជាបានពួនស្ទាក់ចាំចាប់ជនរងគ្រោះនិងវាយជនរងគ្រោះបណ្ដាលឱ្យស្លាប់ប្រាកដមែន ។ ចម្លើយសារភាពទាំងនេះមានភាពស៊ីចង្វាក់គ្នាទៅនឹងភស្តុតាងដែលសមត្ថកិច្ចបានចាប់យកនៅកន្លែងកើតហេតុ ។ រាល់ទង្វើរបស់ជនជាប់ចោទពិតជាមានភស្តុតាងនិងពិរុទ្ធភាពគ្រប់គ្រាន់ពីបទឃាតកម្មគិតទុកជាមុនដែលតម្រូវឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ដូចផ្នែកសំអាងហេតុ ត្រង់ចំណុចទី២ ,ទី៣ និងទី៤ នៃសាលដីកាព្រហ្មទណ្ឌលេខ ២៩ ក្រIV "ណ" ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ នោះតុលាការកំពូលពិចារណាឃើញថា ជាសេចក្ដីសន្និដ្ឋានមានមូលដ្ឋានសំអាងលើអង្គហេតុ ភស្តុតាង និងអង្គច្បាប់ត្រឹមត្រូវហើយ លើកលែងតែផ្នែកអនុវត្តច្បាប់ចំពោះជនជាប់ចោទឈ្មោះ [redacted] ខែសា ដែលនៅអនីតិជននៅឡើយ ដែលគប្បីអនុវត្តតាមបទប្បញ្ញត្តិ មាត្រា ១៦០ ត្រង់កថាខណ្ឌទី១ ចំណុចទី២ នៃក្រមព្រហ្មទណ្ឌ ។

៥-យល់ឃើញថា ផ្នែកបណ្ដឹងសាទុក្ខលេខ ១៧៧ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] ខែសា ធ្វើឡើងមានមូលហេតុនៃនៃបណ្ដឹងសាទុក្ខសមស្របតាមបញ្ញត្តិមាត្រា ៤១៩ ត្រង់ចំណុចទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំណែកឯផ្នែកបណ្ដឹងសាទុក្ខលេខ ១៧៧ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] ធានី ធ្វើឡើងមិនមានមូលហេតុនៃបណ្ដឹងសាទុក្ខសមស្របតាមបញ្ញត្តិមាត្រា ៤១៩ ក្រមនីតិវិធីព្រហ្មទណ្ឌទេ ។

៦-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ២៩ ក្រIV "ណ" ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលសម្រេចសេចក្ដីមកនេះត្រឹមត្រូវហើយ លើកលែងតែផ្នែកសេចក្ដីវិនិច្ឆ័យ ត្រង់ចំណុចទី២ នៃសាលដីកា ដែលបានសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៦ "ខ" ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ធំទុកជាបានការ ត្រង់ផ្នែកសេចក្ដីវិនិច្ឆ័យ ចំណុចទី១ ផ្ដន្ទាទោសជនជាប់ចោទ៖

៧-ឈ្មោះ [redacted] ខែសា ហៅ សាល ភេទប្រុស អាយុ ១៧ ឆ្នាំ ជាតិខ្មែរ (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ១៥ (ដប់ប្រាំ) ឆ្នាំ ដែលគប្បីបដិសេធចោល។



Scanned with CamScanner

## ហេតុដូច្នេះ
## សម្រេចសេចក្តី

១.**ក-ទទួល**ផ្នែកបណ្តឹងសាទុក្ខលេខ ១៧៧ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ ផ្លន ខែសា ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

**ខ-បដិសេធ**ផ្នែកបណ្តឹងសាទុក្ខលេខ ១៧៧ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១ របស់ជនជាប់ចោទ ឈ្មោះ[redacted]ផានី ។

២.**តម្កល់**សាលដីកាព្រហ្មទណ្ឌលេខ ២៩ ក្រIV ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការ ។ លើកលែងតែផ្នែកសេចក្តីវិនិច្ឆ័យ ត្រង់ចំណុចទី២ នៃសាលដីកា ដែលបានសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៦ "ខ" ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ធំ ទុកជាបានការ ត្រង់ផ្នែកសេចក្តីវិនិច្ឆ័យ ចំណុចទី១ ផ្តន្ទាទោសជនជាប់ចោទ៖

១-ឈ្មោះ ផ្លន[redacted]ហៅ សាល ភេទប្រុស អាយុ ១៧ ឆ្នាំ ជាតិខ្មែរ (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ១៥ (ដប់ប្រាំ) ឆ្នាំ *ត្រូវបដិសេធចោល*។

៣.**បញ្ជូន**សំណុំរឿងព្រហ្មទណ្ឌលេខ ២៥៥ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីជំនុំជម្រះសាជាថ្មី ត្រង់ចំណុចដែលបានបដិសេធ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ជាប្រធាន |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| លោកស្រី | [redacted] | ជាក្រឡាបញ្ជី |

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។**

**បានឃើញ**

ថ្ងៃសុក្រ ១២រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២
**ប្រធានអង្គជំនុំជម្រះ**

[redacted]

ថ្ងៃសុក្រ ១២រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២
**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner